ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : ខ្លាគ្រហឹម

ភូមិ : ខ្លាគ្រហឹម

ឃុំ : អំពិលទឹក

ស្រុក : កំពង់ត្រឡាច

ខេត្ត : កំពង់ឆ្នាំង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

# រយៈពេល ៣ ឆ្នាំ

# (២០០៨-២០១០)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | : | ខ្លាក្រហឹម |
| ភូមិ | : | ខ្លាក្រហឹម |
| ឃុំ | : | អំពិលទឹក |
| ស្រុក | : | កំពង់ត្រឡាច |
| ខេត្ត | : | កំពង់ឆ្នាំង |

# ផែនការគ្រប់គ្រង
# តំបន់នេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **ខ្នាគ្រហឹម** ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី **១២** ខែ **មិថុនា** ឆ្នាំ **២០០៧** និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី ១១ ខែ **មករា** ឆ្នាំ **២០០៨**។

សហគមន៍នេសាទ **ខ្នាគ្រហឹម** មានទីតាំងស្ថិតនៅក្នុង ភូមិ **ខ្នាគ្រហឹម** ឃុំ **អំពិលទឹក** ស្រុក **កំពង់ត្រឡាច** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **២០២** នាក់ ស្រីចំនួន **៩៥** នាក់ និងមានគណៈកម្មការចំនួន**១១** នាក់ ស្រីចំនួន **១** នាក់ ។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន **៣៨៤** គ្រួសារ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ

- ចុះបង្ក្រាបបទល្មើសនេសាទស្បៃមុង
- ចុះធ្វើការទប់ស្កាត់ការកាប់ព្រៃលិចទឹក
- ចុះល្បាត

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាជនរស្ត:

- ចំនួនប្រជាពលរដ្ឋក្នុងភូមិសរុបក្នុងសហគមន៍នេសាទមាន **១៧៣៨** នាក់ប្រុស **៨៥១** នាក់ ស្រី **៨៨៧** នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន **៣៦២** គ្រួសារ ខ្មែរឥស្លាមចំនួន **គ្មាន** អាណិកជនវៀតណាមចំនួន **គ្មាន**។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៧១ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៥ នាក់ ស្រី ១ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៥៦ នាក់ ស្រី ៣០ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ៤៦ នាក់ ស្រី ១៤ នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន គ្មាន
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ **១០០%**។ ក្រៅពីនេះមានអ្នកកាន់សាសនាអ៊ិស្លាម ប្រមាណ **គ្មាន %** សាសនាកាតូលិកប្រមាណ **គ្មាន %**
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន **២៥** នាក់ ស្រី **៦** នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន **១២៨០** នាក់ស្រី **៥៦៥** នាក់ កំរិតមធ្យមសិក្សា ចំនួន **៦៦១** នាក់ ស្រី **៣១៦** នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន **២** ស្រី **គ្មាន**

**ខ-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

- ធ្វើនេសាទចំនួន ៣៨៤ គ្រួសារ
- ធ្វើស្រែចំនួន ៣៨៤ គ្រួសារ ទំហំ ៦៦៥ ហិកតា
- ជាងផ្ទះចំនួន ៣ គ្រួសារ
- ធ្វើចំការចំនួន ២ គ្រួសារ ទំហំ ២ ហិកតា
- ធ្វើសិប្បកម្មចំនួន ២០០ គ្រួសារ
- លក់ដូរចំនួន ៤ គ្រួសារ
- កែច្នៃផលនេសាទចំនួន ២០២ គ្រួសារ

## ៣. កន្លែងនេសាទសហគមន៍ និងធនធានវារីផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ **ខ្នាគ្រហឹម** ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទលេខ **១៩** ដែននេសាទទឹកសាប ។

កន្លែងនេសាទសហគមន៍ **ខ្នាគ្រហឹម** មានទំហំ **៩០២** ហិកតា និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ :

- ខាងជើងទល់នឹង **ដែនសហគមន៍នេសាទ ភូមិបែកចាន**
- ខាងត្បូងទល់នឹង **ដែនសហគមន៍នេសាទ ភូមិបាកភ្នំ**
- ខាងកើតទល់នឹង **ដងទន្លេសាប**
- ខាងលិចទល់នឹង **ដែនសហគមន៍នេសាទ ភូមិព្រែកខ្នុង និង ភូមិ កៀនរកា**

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ **ខ្នាគ្រហឹម** មានបឹងចំនួន **៣** ព្រែកចំនួន **២** ប្រឡាយចំនួន **១** ត្រពាំងចំនួន **១** បៀចំនួន គ្មាន និងមេទឹកចំនួន ១ ។

- បឹងឈ្មោះ **បឹងជំនីកមន** ទំហំ ១៥ ហិកតា នេសាទពីខែ មេសា ដល់ខែ មិថុនា
- ទន្លេឈ្មោះ **ទន្លេសាប** ទំហំ ៤៧១០ម × ៧៥០ម នេសាទពីខែ មិថុនា ដល់ខែ កញ្ញា
- ព្រែកឈ្មោះ **តាកំ** ប្រវែង ១២០០ម នេសាទពីខែ មិថុនា ដល់ខែ មេសា
- ប្រឡាយឈ្មោះ **ជំនីកមន** ប្រវែង ៤០០ម នេសាទពីខែ មិថុនា ដល់ខែ មេសា
- ស្ទឹងឈ្មោះ **កំបុត** ប្រវែង ១១០២ម នេសាទពីខែ មិថុនា ដល់ខែ មេសា

- ត្រពាំងឈ្មោះ **បឹងជីក្រហម** ប្រវែង ១៥០ម × ៤០ម នេសាទពីខែ មិថុនា ដល់ខែ កញ្ញា
- អាងទឹកឈ្មោះ **ជំនីកមន** ទំហំ ១៥ ហិកតា នេសាទពីខែ មិថុនា ដល់ខែ កញ្ញា
- មេទឹកឈ្មោះ **កន្លែងថ្នាន់** ប្រវែង បណ្តោយ ១០០០ម ទទឹង ៥០០ម នេសាទពីខែ មិថុនា ដល់ខែ កញ្ញា
- ស្រះ ៣០០ ទំហំ ហិកតា នេសាទពីខែ ដល់ខែ គ្មាន
- ព្រៃលិចទឹកមានទំហំសរុបទំហំ **៤** ហិកតា
- ព្រៃឈ្មោះ **ជំនីកមនកន្លែងសួង** ទំហំ ២ ហិកតា
- ព្រៃឈ្មោះ **ស្ទឹងកំបុតកន្លែងថ្នាន់** ទំហំ ២ ហិកតា
- ដីទំនាបលិចទឹកមានទំហំសរុប **៣៣៣២** ហិកតា ។

## គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

- បឹងឈ្មោះ **បឹងជំនីកមន** ទំហំ ១៥ ហិកតា ( បណ្តោយ១២០០ម ទទឹង ១២០០ម )

## ឃ. ធនធានជលផល

- ប្រភេទត្រី ( ត្រីរ៉ស់ ឆ្តោរ រៀល ក្រាញ់ ក្រុស អណ្តែង កញ្ចុះ ស្លាត ច្រកែង ក្រម៉ម សណ្តាយ ក្ដី ដំរី ព្រលូង កន្ទ្រង់ព្រេង កន្ទ្រប់ ព្រួល ឆ្ពិន អណ្តែង ខ្ញឹង ខ្មាន់ កាហែ លិញ ក្បាលឡាន កាហោ ក្លាំងហាយ ក្រពាត់ ខ្ញឹង ឆ្លូញ ឆ្លាំង កំភ្លាញ ជន្លាសភ្លុក ជញ្ជូញមាន់ ចង្វាននោង កេស )
- ប្រភេទវារីសត្វ ( អណ្តើក ពស់ ក្តាម អន្ទង់ ខ្យង ខ្ចៅ គ្រុំ លៀស កង្កែប )
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ (រាំង ត្រស់ ត្នួ បបួយ អាញា ថ្មើមអណ្តើក ភ្នំភ្លើង អញ្ចាញ ឬស្សីព្រៃ ទានព្រៃ ខ្នាយមាន់ កក់ ឈូក វិចង់ ក្រចាប់ កំប្លោក សារាយ ព្រលិត ចំបួង កំពីងពួយ) (ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទីភ្ជាប់មកជាមួយ) ។

# ៤. ការធ្វើនេសាទ

## ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ១៨០ នាក់ ស្រី ១៥ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ១៥៥៨ នាក់ស្រី ៨៧២ នាក់ ។
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ៥៦ នាក់ស្រី ១៨ នាក់

## ៩. ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ.......ដល់ ខែ........) |
|---|---|---|---|---|
| មង | ដៃ | ៣៦០ | (២ > ៦ ) ២១៦០០ម | មិថុនា - ធ្នូ |
| សន្ទូចរនង | ១៨០ | ៣៦០០ | (១២ > ១៥ ) ២១៦០០ម | មិថុនា - ធ្នូ |
| លប | ៤ | ៣ | ១៥ > ១៨០ ដម | មិថុនា - ធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| | ៨ | ២ > ៥ តោន | ១៥ > ២៤ សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មង | ៣១១៦ | ១៨៦៩៦ម | ២,៥ > ៦,៥ |
| សន្ទូចរនង | ១៥០៨០០ | ១៥០៨០០ម | ១២ > ១៥ |
| លប | ៣០ | ៦០ | ០,៨០-០,៩០ ដម -១,៥០ ម |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន | ១៥៥៨ | ១-៣ តោន | ៥-១០ សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មង | ៦០ | ៣៦០០ | ២,៥-៥,៥ |
| សន្ទូចរនង | ២០០ | ២០០ | ១០-១៥ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ចាប់ចំហៀង | ១០ | ២-៣ តោន | ៦-១២ សេះ |
| ចាប់បាត | ៥ | ២-៤ តោន | ១០-១៥ តោន |

**គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីរៀល | ៤៦៤៤០ គក្រ | ៤១២៨០ គក្រ | ៨៧៧២០ គក្រ |
| ក្តាម ខ្យង | ៤២០ គក្រ | ៥២០ គក្រ | ៩៤០ គក្រ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទ **ភូមិខ្នាគ្របឹម** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុងទំនាបលិចទឹកក្នុងរដូវដំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

| **ឈ្មោះ/ទីតាំង កន្លែងនេសាទ** | **ពេលវេលា ធ្វើនេសាទ** | **ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ** | | | **ផ្សេងៗ** |
|---|---|---|---|---|---|
| | | **ប្រភេទ** | **ទំហំ/ប្រវែង** | **ចំនួន** | |
| ជំនីកមន | មិថុនា-កញ្ញា | មង សន្ទូច | ១២ — ១៥,៦០ | ៣៤៤ | |

## គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ជំនីកមន | ៥០០ម×៤០០ម | ៣០០ម × ២៥០ម | ជីកជំរៅ ១ម =៤០០០រ | មេសា ២០០៨ | មិថុនា ២០០៨ | |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទ នៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ជំនីកមន | ៧០០ម×៤០០ម | ធនធានធម្មជាតិ មានជីវចំរុះ | ដាំឡើងវិញ | កុម្ភៈ ២០០៨ | កក្កដា ២០០៨ | |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើ ដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១-ដាំព្រៃលិចទឹក | ៧០០ម×៤០០ម | រាំង ត្រស់ | ដាំឡើងវិញ | កុម្ភៈ ២០០៨ | កក្កដា ២០០៨ | |
| ២-ថែរក្សា និង រំលោះព្រៃលិចទឹក | ៧០០ម×៤០០ម | រាំង ត្រស់ | ដាំឡើងវិញ | កុម្ភៈ ២០០៨ | កក្កដា ២០០៨ | |

## គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ | ២០ | អណ្តែង ប្រា | អណ្តែង ២០គក្រ ប្រា ៣០០ ក្បាល | មេសា ២០០៨ មេសា ២០០៩ | មិថុនា ២០០៨ មិថុនា ២០០៩ |

## គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | | | | | |
| ភាគទានប្រចាំឆ្នាំ | ប្រមូល | កុម្ភៈ ២០០៨ | មេសា ២០០៩ | ៥០០៛×២០២=១០១៥០០ ៛ | |
| ជំនួយសប្បុរសជន និងអង្គការនានា | គ្មាន | គ្មាន | គ្មាន | គ្មាន | |

## គ-៧ ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាពសហគមន៍

| ប្រភេទមុខរបរ | សកម្មភាព និងចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| ចិញ្ចឹម ត្រី, ជ្រូក, មាន់ | មាន់ ៣ក្បាល/គ្រួសារ (១០គ្រួសារ)<br>ជ្រូក២ក្បាល/គ្រួសារ (១០គ្រួសារ) | ២០០៨ | ២០១០ |
| ដាំបន្លែ (ននោង, សណ្តែកគួ, ស្ពៃខៀវ, ស្ពៃចង្កឹះ...) | ២០ គ្រួសារ | ២០០៨ | ២០១០ |
| បណ្តុះផ្សិត | ១គ្រួសារ/២រង (១០គ្រួសារ) | ២០០៨ | ២០១០ |

## គ-៨ ផែនការបោះបង្គោលព្រំប្រទល់សហគមន៍

| ចំនួនបង្គោល | ចំណុចត្រូវបោះ | អ្នកទទួលខុសត្រូវ | ពេលវេលា | | ផ្សេងៗ |
|---|---|---|---|---|---|
| | | | ចាប់ផ្តើម | បញ្ចប់ | |
| ៤ បង្គោល (PIU) | តាមចំណុចដែលបានកំនត់ក្នុងផែនទីសហគមន៍ | គណៈកម្មការសហគមន៍នេសាទ | កុម្ភៈ ២០០៨ | មិនា ២០០៨ | ត្រូវការជំនួយ និងការសហការពី ស្ថាប័នជំនាញនិងអង្គការនានា |

## គ-៩ ផែនការផ្សព្វផ្សាយ និងលើកកំពស់ការយល់ដឹង

| ប្រធានបទ | ក្រុមគោលដៅ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៣ និង១០នៃឆ្នាំនិមួយៗ | PIU និង FAO |
| សារៈប្រយោជន៍នៃធនធានធម្មជាតិ | សមាជិក និង | រៀងរាល់ខែ ៥នៃឆ្នាំនិមួយៗ | PIU និង FAO |

| | | | |
|---|---|---|---|
| ផែនទីកំណត់ព្រំប្រទល់កន្លែងនេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៨ នៃឆ្នាំនិមួយៗ | PIU និង FAO |
| ផែនការគ្រប់គ្រងកន្លែងនេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ១ នៃឆ្នាំនិមួយៗ | PIU និង FAO |
| ច្បាប់ជលផល និងច្បាប់ផ្សេងៗទាក់ទងដល់ការគ្រប់គ្រងសហគមន៍នេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៥ នៃឆ្នាំនិមួយៗ | PIU និង FAO |
| ការគ្រប់គ្រង និងសារៈប្រយោជន៍នៃព្រៃលិចទឹក | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ១ នៃឆ្នាំនិមួយៗ | PIU និង FAO |
| ផលប៉ះពាល់ការប្រើប្រាស់ថ្នាំពុលកសិកម្ម និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ២ នៃឆ្នាំនិមួយៗ | PIU និង FAO |

## គ-១០ ផែនការពង្រឹងសមត្ថភាពសហគមន៍

| ផែនការ | ប្រធានបទ/ជំនាញ | ក្រុមគោលដៅ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ពង្រឹងស្ថាប័ន និងការងារគ្រប់គ្រង | ការធ្វើកំណត់ហេតុ និង របាយការណ៍ | គណៈកម្មការស.ន | កុម្ភៈ ២០០៨ | PIU និង FAO |
| | របៀបសរសេរខិតរដ្ឋបាល | គណៈកម្មការស.ន | កក្កដា ២០០៨ | PIU និង FAO |
| | រៀបចំទុកដាក់ឯកសារសហគមន៍ និងរបៀបកត់ត្រាប្រចាំថ្ងៃ | គណៈកម្មការស.ន | មិថុនា ២០០៨ | PIU និង FAO |
| | ការគ្រប់គ្រងថវិកា | គណៈកម្មការស.ន | កុម្ភៈ ២០០៨ | PIU និង FAO |
| | ការដោះស្រាយទំនាស់ | គណៈកម្មការស.ន | | PIU និង FAO |
| | ការទំនាក់ទំនង និង សរសេរសំណើសុំថវិកា | គណៈកម្មការស.ន | មេសា ២០០៨ | PIU និង FAO |
| | រៀបចំបណ្តាញសហគមន៍ | គណៈកម្មការស.ន | សីហា ២០០៨ | PIU និង FAO |
| | ទស្សនៈកិច្ចសិក្សារផ្លាស់ប្តូរបទពិសោធន៍ | គណៈកម្មការស.ន | ១ដង/ឆ្នាំ | PIU និង FAO |
| បណ្តុះបណ្តាលបច្ចេកទេស | បណ្តុះ និងដាំព្រៃលិចទឹក | សមាជិក និង គណៈកម្មការស.ន | កញ្ញា ២០០៨ | PIU និង FAO |
| | ចិញ្ចឹមត្រី និងសត្វ | សមាជិក និង គណៈកម្មការស.ន | កុម្ភៈ ២០០៨ | PIU និង FAO |
| | បណ្តុះផ្សិត | សមាជិក និង គណៈកម្មការស.ន | មិនា ២០០៨ | PIU និង FAO |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម:

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៏ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែល ទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈ ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរក ថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួល បានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រង សហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធ សំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ខ្លាគ្រហឹម រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | - ផ្សព្វផ្សាយផែនការប្រើប្រាស់ឧបករណ៍នេសាទដល់សមាជិកសហគមន៍ទាំងអស់ និងអ្នកមកពីខាងក្រៅ<br>- ចុះត្រួតពិនិត្យ និងតាមដានជាប្រចាំ | - សមាជិក និងអ្នកមិនមែនជាសមាជិកសហគមន៍ទាំងអស់បានជ្រួតជ្រាបពីផែនការ<br>- ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ នាំឱ្យត្រីមានការកើនឡើង | - ចំណាយលើការផ្សព្វផ្សាយ ១៥០ ដុល្លា<br>- ចំណាយលើការចុះល្បាត ត្រួតពិនិត្យតាមដាន ២០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ប្រាក់បដិភាគរបស់សហគមន៍ | ២០០៨ | ២០១០ | |
| ២. ការកែលំអដែននេសាទ | ដំនីកមន, ជីគជំរៅ,ទំហំ ៣០០ម × ២៥០ម | -ជីវភាពកើនឡើង<br>-ជីវភាពសំបូររុងរឿង<br>-រក្សាមេពូជ | ២០០០ ដុល្លា | -អង្គការ<br>-ជំនាញ | មេសា ២០០៨ | មិថុនា ២០០៨ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស | ជំនីកមន, ទំហំ ៧០០ម × ៤០០ម | -ជីវភាពកើនឡើង<br>-ជីវភាពសំបូររុងរឿង<br>-រក្សាមេពូជ | ២០០០ ដុល្លា | -អង្គការ<br>-ជំនាញ | កុម្ភៈ ២០០៨ | កក្កដា ២០០៨ | |
| ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក | ដាំព្រៃលិចទឹកទំហំ ៧០០ម × ៤០០ម រាំង , ត្រស់ | -រក្សាមេពូជត្រី<br>-សំបូរសត្វស្លាប និងធនធានជលផល។<br>- ជីវភាពប្រជាជនកើនឡើង | ៣០០ ដុល្លា | ជំនាញជលផល | កុម្ភៈ ២០០៨ | កក្កដា ២០០៨ | |
| ៥- ផែនការអភិវឌ្ឍ | ចិញ្ចឹមត្រីប្រា និង អណ្តែង | -ជីវភាពប្រជាជនកើនឡើង<br>-បង្កើនជីវភាពគ្រួសារ | ១០០ ដុល្លា | សំបុរសជន | មេសា | មិថុនា | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| នីវារីវប្បកម្ម | ក្នុងស្រះ ២០ × ២ ត្រីអណ្ដែង ២០គក្រ.ប្រា ៣០០ក្បាល | | | អង្គការ និង ជំនាញ | ២០០៨ | ២០០៨ | |
| ៦- ផែនការរកប្រាក់ចំណូលសហគមន៍ | - ប្រមូលប្រាក់សមាជិកភាព និង ភាគទានប្រចាំឆ្នាំ<br>- ស្វែងរកជំនួយបន្ថែមពីអង្គការ និងសប្បុរសជននានា | សមាជិកស.នទាំងអស់នឹងបង់ប្រាក់តាមការកំនត់ក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង<br>- អង្គការ និងសប្បុរសជននានា នឹងជួយគាំទ្រតាមរយៈការផ្ដល់សំភារៈ និងថវិកាដល់ស.ន | - គ្មានការចំណាយ | - | ២០០៨ | ២០១០ | |
| ៧- ផែនការបង្កើនមុខរបរ ទ្រទ្រង់ជីវភាព | វិភាគនិងចាត់អាទិភាពជំរើសមុខរបរចិញ្ចឹមជីវិត ស្វែងរកអង្គការស្ថាប័នគាំទ្រ<br>- រៀបចំសំណើសុំថវិកា | - ជំរើសមុខរបរចិញ្ចឹមជីវិតត្រូវបានកំនត់ និងចាត់អាទិភាព សំណើសុំថវិកាត្រូវបានរៀបចំ និងទទួលបានការគាំទ្រពីអង្គការនានា | - ចំណាយសរុប ៥០០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | ២០០៨ | ២០១០ | |
| ៨- ផែនការបោះបង្គោល ព្រំប្រទល់សហគមន៍ | សហការជាមួយជំនាញផែនទីកំនត់ទីតាំងត្រូវបោះបង្គោល<br>- ស្វែងរកថវិកាគាំទ្រ | -បង្គោលត្រូវបានបោះត្រឹមត្រូវតាមចំនុចដែលកំនត់លើផែនទី ស.នមានព្រំប្រទល់ច្បាស់លាស់ កាត់បន្ថយជម្លោះ | - ចំណាយសរុប ៣០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់ | កុម្ភៈ ២០០៨ | មិនា ២០០៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | សហគមន៍ | | | |
| ៩- ផែនការផ្សព្វផ្សាយ និងបង្កើនការយល់ដឹង | - ផ្សព្វផ្សាយឱ្យស.គបានយល់ដឹងពី លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធ និងស.ន | - ស.គបានយល់ដឹង និងអនុវត្តតាម | - ១០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មករា ២០០៨ | ធ្នូ ២០១០ | |
| ១០- ផែនការពង្រឹងសមត្ថភាពសហគមន៍ | - បង្កើនសមត្ថភាពស.គទាំងជំនាញ គ្រប់គ្រងស្ថាប័ន និងបច្ចេកទេស | ស.គចេះជំនាញផ្សេងៗទាក់ទិន និងការងារគ្រប់គ្រងស្ថាប័ន និងបច្ចេកទេស | - ១៥០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មករា ២០០៨ | ធ្នូ ២០០៨ | |

| សកម្មភាព | ឆ្នាំ ២០០៨ | | | | | | | | | | | | ឆ្នាំ ២០០៩ | | | | | | | | | | | | ឆ្នាំ ២០១០ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 1 |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២. ការកែលំអដែននេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧. ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាព | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨. ផែនការបោះបង្គោលព្រំប្រទល់ស.គ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩. ផែនការផ្សព្វផ្សាយនិងបង្កើនការយល់ដឹង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១០. ផែនការពង្រឹងសមត្ថភាពសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

............ ថ្ងៃទី ...9... ខែ ...9... ឆ្នាំ ២០០8

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

បានឃើញ និងបញ្ជូនមក

លោកនាយខណ្ឌរដ្ឋបាលជលផល

**នាយសង្កាត់រដ្ឋបាលជលផល**............

...........ថ្ងៃទី....10.....ខែ....9.........ឆ្នាំ ២០០8

**បានឃើញ**

**មេឃុំ**............

...............ថ្ងៃទី ...10... ខែ ...9............ឆ្នាំ ២០០8

លេខ :.................

លេខ :...389...

លេខ :..02...

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ.............ឆ្នាំ ២០០

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

បានឃើញ និងបញ្ជូនមក

. ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ "

...........ថ្ងៃទី...27...ខែ...11.......ឆ្នាំ ២០០8

**នាយអធិការដ្ឋាន រដ្ឋបាលជលផល**............

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋាន រដ្ឋបាលជលផល............

...........ថ្ងៃទី...21...ខែ...10....ឆ្នាំ ២០០8

**នាយខណ្ឌរដ្ឋបាលជលផល**............